**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា

## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ថ្លែងក្នុងឱកាសបិទសន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២៣ នៅសណ្ឋាគារឯករាជ្យ ខេត្តព្រះសីហនុ ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៣

ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលកំពុងមានវត្តមានដ៏ឧត្តុង្គឧត្តមក្នុងសន្និបាតនាពេលនេះ!

ឆ្លងកាត់ការបង្ហាញពីវឌ្ឍនភាព ប្រសិទ្ធភាព និងសមិទ្ធផល ជាពិសេសមេរៀនជាបទពិសោធន៍ល្អៗដែលបានមកពីការអនុវត្តរបស់សមាជិក សមាជិកា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នៅទូទាំងប្រទេសនៅក្នុងអង្គសន្និបាតនាពេលនេះ តាងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមអបអរសាទរ និងកោតសរសើរដោយស្មោះចំពោះសមាជិក សមាជិកា នៃអង្គសន្និបាតទាំងអស់ ដែលបានខិតខំប្រឹងប្រែងយ៉ាងសកម្មចូលរួមក្នុងការងារប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ឱ្យទទួលបាននូវជោគជ័យជាបន្តបន្ទាប់គួរជាទីមោទនៈ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

ជោគជ័យដែលយើងទទួលបាន គឺពិតជាបានមកពីការរួមចំណែករបស់សមាជិក សមាជិកា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដែលជាតំណាងក្រសួង ស្ថាប័ន រាជធានី ខេត្ត របស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ និងបណ្តាញក្រុមប្រឈមខ្ពស់នឹងការចម្លងមេរោគអេដស៍។ ដោយឈរលើគោលការណ៍ "មិនទុកនរណាម្នាក់ចោលដោយមិនបានទទួលការយកចិត្តទុកដាក់" អាជ្ញាធរមូលដ្ឋាន មន្ត្រីសុខាភិបាល និងអ្នកធ្វើការងារសង្គមគួរតែអនុវត្តអភិក្រមយកប្រជាជនជាគោល (people-centered)។ ក្នុងនោះ ការស្តាប់ និងរៀនសូត្រពីគ្នាទៅវិញទៅមកក្នុងចំណោមភាគីពាក់ព័ន្ធគឺជាការចាំបាច់ក្នុងការដកចេញរបាំងឧបសគ្គ និងសម្រួលឱ្យប្រជាជនគន្លឹះនិងអ្នកផ្ទុកមេរោគអេដស៍ទទួលបានសេវាប្រកបដោយគុណភាព និងសមធម៌។ ថ្នាក់

ដឹកនាំនៅគ្រប់កម្រិតត្រូវធ្វើឱ្យសម្រេចគោលដៅ៩៥-៩៥-៩៥ ដោយចូលរួមធ្វើការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ប្រកបដោយថាមវន្ត សមាហរណកម្ម និងចីរភាព។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

ឆ្លងតាមការពិភាក្សាយ៉ាងសកម្មនៅក្នុងអង្គសន្និបាតនាពេលនេះ ខ្ញុំសូមចូលរួមចំណែកផ្តល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោម ៖

១) ធានាឱ្យបាននូវចីរភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ គ្រប់លំដាប់ថ្នាក់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពិសេសក្នុងឃុំ សង្កាត់ ទាំងអស់នៅទូទាំងប្រទេស និងធ្វើការបញ្ជ្រាបនិងបញ្ចូលសកម្មភាពឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ទៅក្នុងផែនការរួមរបស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ស្រុក ខណ្ឌ និងឃុំ សង្កាត់។

២) ពង្រឹង និងពង្រីកសេវាបង្ការ ធ្វើតេស្ត និងថែទាំព្យាបាលមេរោគអេដស៍ និងជំងឺអេដស៍រួមគ្នា ជាពិសេសក្រុមប្រឈមនៅតាមសហគមន៍ ដោយអនុវត្តការប្រើប្រាស់ស្រោមអនាម័យ១០០% វិធីលេបថ្នាំបង្ការជាមុននៅពេលមានការប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍ ប្រិប (PrEP) វិធីលេបថ្នាំបង្ការក្រោយពេលមានការប្រព្រឹត្តប្រឈមនឹងការឆ្លងមេរោគអេដស៍ ប៉ិប (PEP) និងការធ្វើតេស្តរកមេរោគអេដស៍ដោយខ្លួនឯង (HIV Self-Testing) រួមនឹងការប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍ឱ្យបានត្រឹមត្រូវ និងជាប់លាប់តាមការណែនាំរបស់គ្រូពេទ្យ។

៣) អាជ្ញាធរថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលរាជធានី ខេត្ត និងក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវសហការជំរុញនីតិវិធីនៃការបែងចែក និងប្រើប្រាស់កញ្ចប់ថវិកាជាតិ ៨០លានរៀល ៦០លានរៀល និង៤០លានរៀល សម្រាប់ការងារប្រយុទ្ធនឹងជំងឺអេដស៍ ថ្នាក់ខេត្ត ស្រុក និងថ្នាក់ឃុំ សង្កាត់។

៤) រក្សាស្រោមអនាម័យឱ្យមាននៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា ដែលត្រូវការប្រើប្រាស់ប្រកបដោយគុណភាពខ្ពស់ និងបន្តលើកទឹកចិត្តដល់ក្រុមយុវវ័យដែលរួមភេទដូចគ្នាឱ្យទៅពិនិត្យឈាមរកមេរោគអេដស៍ និងប្រើប្រាស់កម្មវិធីបង្ការការចម្លងមេរោគអេដស៍តាមរយៈការប្រើស្រោមអនាម័យ១០០% នៅពេលរួមភេទ។

៥) ត្រូវបន្តការគាំទ្រដល់អង្គការសង្គមស៊ីវិល និងចលនាសហគមន៍ ដើម្បីបំពេញបន្ថែមដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល។

៦) សូមអំពាវនាវឱ្យមានការចូលរួមយ៉ាងសកម្ម និងគាំទ្រខ្លាំងក្លាដល់បុគ្គលិកសុខាភិបាល ក្រសួង និងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ផ្នែកឯកជន ក្រុមប្រជាជនគន្លឹះ ដើម្បីធ្វើការជាមួយគ្នាដោយជិតស្និទ្ធ និងបំពេញឱ្យគ្នាទៅវិញទៅមក ដើម្បីបញ្ចប់អេដស៍នៅឆ្នាំ២០២៥។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

ខ្ញុំមានក្តីសង្ឃឹមជឿជាក់ថា អនុសាសន៍ទាំងអស់ខាងលើនេះ អាចនឹងយកទៅប្រើប្រាស់ក្នុងការអនុវត្តគម្រោងផែនការសកម្មភាពជាតិទូលំទូលាយ និងពហុវិស័យ ឆ្លើយតបទៅនឹងការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ក្នុងឆ្នាំខាងមុខឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យជូនឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ ឱ្យទទួលបានសុខភាពល្អ និងសម្រេចបាននូវជោគជ័យថ្មីៗបន្ថែមទៀត នាឆ្នាំ២០២៤ខាងមុខនេះ។

ខ្ញុំសូមប្រកាសបិទ "**សន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២៣**" ចាប់ពីពេលនេះតទៅ។

សូមអរគុណ។